## Đề thi: Đọc - Viết 02

Họ và tên Học viên:...........................................................................................

***Câu 1***: ចូរអានអត្ថបទ និងឆ្លើយសំណួរនៅខាងក្រោម ។

នៅព្រៃមួយ មានសត្វចាបនិងដំរីដណ្ដើមគ្នាធ្វើជាមេ ។

ថ្ងៃមួយ ដំរីបបួលចាបផឹកទឹកភ្នាល់គ្នា ។ បើអ្នកណាផឹកបានច្រើនជាង អ្នកនោះជាអ្នកឈ្នះ ។ ចាបក៏យល់ព្រម ហើយហើរនាំផ្លូវដំរីកាត់ព្រៃភ្នំទៅកាន់សមុទ្រ ។ ពេលនោះ ទឹកសមុទ្រកំពុងជោរ ចាបក៏ឱ្យដំរីផឹកទឹកមុន ។ ទឹកសមុទ្រប្រៃពិបាកលេបណាស់ តែដោយចង់ឈ្នះ ដំរីខំផឹកឥតឈប់ ។ ទឹកសមុទ្រនៅតែជោរឡើងដល់ពោះវា ទើបដំរីឈប់ផឹក ។ លុះទឹកនាច ចាបក៏ហើរទៅមាត់ទឹកឱនក្បាលជ្រលក់ចំពុះក្នុងទឹកធ្វើជាផឹក ។ ទឹកស្រកចុះ ចាបក៏លោតតាមទឹកនាចធ្វើជាផឹករហូតដល់ជើងដំរី ។ ចាបផឹកទឹករហូត ទាល់តែដំរីឃាត់ ។

តាំងពីពេលនោះមក ចាបក៏បានធ្វើជាមេ ដោយសារប្រាជ្ញាឈ្លាសវៃរបស់ខ្លួន ។

សំណួរ

១.តើចាបនិងដំរីដណ្ដើមគ្នាធ្វើអ្វី ?

________________________________________________

________________________________________________

២.តើចាបហើរនាំដំរីទៅណា ?

________________________________________________

________________________________________________

៣.តើចាបនិងដំរីភ្នាល់គ្នាធ្វើអ្វី ?

________________________________________________

________________________________________________

៤.តើចាបធ្វើដូចម្ដេច ទើបឈ្នះដំរី ?

________________________________________________



LIVEWORKSHEETS

___________________________________________________________________

**Câu 2**: ចូរពន្យល់ពាក្យ ព្រាន។

___________________________________________________________________

___________________________________________________________________

**Câu 3**: ចូររកពាក្យន័យដូចនឹងពាក្យ ៖ "និទាន " ។

___________________________________________________________________

___________________________________________________________________

**Câu 4**: ចូររកពាក្យផ្ទុយនឹងពាក្យខាងក្រោម

ក្ដៅ ≠ ______________ ឈ្នះ ≠ ______________

**Câu 5**: ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ។

| | | | | |
|---|---|---|---|---|
| ឈើ | ទទួលទាន | ភ្ញៀវ | សម្អាត | សម័យ |

១.ផ្ទះរបស់ខ្ញុំសង់អំពី _________ ប្រក់ក្បឿង ។

២.នៅក្នុងផ្ទះនេះមានបន្ទប់ទទួល ________ បន្ទប់ដេក បន្ទប់ ________ អាហារ ។

៣.វត្ថុប្រើប្រាស់នៅក្នុងផ្ទះរបស់ខ្ញុំ មិនទំនើបទាន់__________ មែន ប៉ុន្តែខ្ញុំ__________ វាជាប្រចាំ ។

**Câu 6**: *Đồng chí hãy dịch các từ sau sang tiếng Việt.*

ខ្ទឹមខ្ទា ___________ បង្ហាញ___________ ផ្ចិតផ្ចង់___________

ដំបូង ___________ គង់_______________ ភ្លើ_______________

សម្លាញ់___________ ឃើញ______________ ក្មេង___________

ប្រុស ___________

----------- HẾT ----------



LIVEWORKSHEETS